**ព្រះរាជាណាចក្រ កម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ៨៤
ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៦
**<u>សាលដីកា</u>**
លេខៈ៣៤៤
ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០៦

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០៦ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម ........... ជាប្រធាន
២-លោក ............ ជាចៅក្រមរបាយការណ៍
៣-លោក ........... ជាចៅក្រម
៤-លោក ........... ជាចៅក្រម
៥-លោក ........... ជាចៅក្រម
៦-លោក ............ ជាចៅក្រម
៧-លោក ........... ជាចៅក្រម
៨-លោក .......... ជាចៅក្រម
៩-លោក ........... ជាចៅក្រម

**<u>ក្រឡាបញ្ជី</u>**

-លោកស្រី ............

**<u>តំណាងមហាអយ្យការ</u>**

-ឯកឧត្តម .................. ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ០៧(ង) ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៦ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៤០ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៥ របស់ សាលាឧទ្ធរណ៍រវាង

ដើមចោទឈ្មោះ តសវថ (ជាម្ចាស់បណ្តឹងសាទុក្ខ) គេទប្រុស អាយុ៣៧ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅសព្វថ្ងៃភូមិបន្ទាយចាស់ ឃុំស្លក្រាម ស្រុកសៀមរាម ខេត្តសៀមរាប ។ ឪពុកឈ្មោះ ជា ប៊ុនរ៉េត (ស)ម្តាយឈ្មោះតៅ អេដែន(ស) ប្រពន្ធឈ្មោះហ៊ាន សុខា ។

មានមេធាវីលោក ........... ។

ចុងចម្លើយឈ្មោះ ជគស (ជាចុងបណ្តឹងសាទុក្ខ)គេទស្រី អាយុ៥៣ឆ្នាំ ជាតិខ្មែរជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅសព្វថ្ងៃភូមិបន្ទាយចាស់ ឃុំស្លក្រាម ស្រុក សៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះជា ឈិន (ស) ម្តាយឈ្មោះខុង ពៅ (ស) ប្តីឈ្មោះឈិន សេងគ្រុយ (ស) កូន០១នាក់ ។

មានមេធាវីលោក .......... ។

**<u>កម្មវត្ថុបណ្ដឹង:</u>**ប្ដឹងសុំសិទ្ធិគ្រប់គ្រងចំណែកដីមរតក

បានឃើញបណ្ដឹងសាទុក្ខលេខ១៩ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៦ របស់ឈ្មោះ តសវថ ប្ដឹងមិនសុខចិត្តនិងសាលដីការដ្ឋប្បវេណីលេខ០៧(ង) ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៦ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចសេចក្ដីសម្រេចទាំងមូល ។

បានឃើញបណ្ដឹងសាទុក្ខ៣០ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ របស់លោកមេធាវី ........... ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ០៧(ង) ចុះថ្ងៃទី១១ ខែមករាឆ្នាំ២០០៦ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចមិនដាក់គុកបង្ខំរូបរាងកាយ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៨៤ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៦ របស់តុលាការកំពូល។

តាមពាក្យបណ្ដឹងចុះថ្ងៃទី១២-០៨-២០០៣ របស់ដើមចោទឈ្មោះ តសវថ ហៅ ជសវថ បានប្ដឹងសុំសិទ្ធិគ្រប់គ្រងចំណែកដីមរតករបស់សពលេឈ្មោះខុង ពៃ ទំហំ៨.៤ម x ៥៥ម ដោយសំអាងហេតុថាជីដូនរបស់ខ្លួនឈ្មោះ ខព បានទទួលមរណភាពកាលពីឆ្នាំ២០០០ ហើយបានបន្សល់ទុកដីមរតក០១ម្លង់ដែលបានកាន់កាប់តាំងពីក្រោយឆ្នាំ១៩៧៩ ហើយដីនេះជីដូនរបស់ខ្លួនជាអ្នកទិញក្នុងតម្លៃ៣ជីមាស ។ កាលពីជីដូនខ្លួននៅរស់ គាត់បានប្រាប់ឱ្យខ្លួននិង ម្ដាយមីងខ្លួន ឈ្មោះ ជគល ចែកគ្នារកស៊ីនៅលើដីនេះចុះ ។ ប៉ុន្តែក្រោយពីជីដូនខ្លួនទទួលមរណភាពេលទៅដល់ពេលនេះឈ្មោះ ជគល ត្រូវជាម្ដាយមីងខ្លួនបានអះអាងថា ដីនេះជាកម្មសិទ្ធិរបស់គាត់តែម្នាក់ឯងមិនព្រមបែងចែកឱ្យខ្លួន ។

តាមពាក្យបណ្ដឹងសារគ្រឡប់ចុះថ្ងៃទី០៤-០៩-២០០៣ ឈ្មោះ ជគល ជាចុងចម្លើយបានប្ដឹងតបថាខ្លួនសុំប្ដឹងសិទ្ធិគ្រប់គ្រងដីមួយប្លង់ទំហំ៩អារ៥២សង់ទីអារ ស្ថិតនៅភូមិបន្ទាយចាស់បានប្ដឹងតបថា ខ្លួនប្ដឹងសុំឃុំស្លក្រោម ស្រុកសៀមរាប ខេត្តសៀមរាប សុំឱ្យឈ្មោះ តសវថ រុះរើតូបចេញពីដី និងសុំឱ្យដុះរើតំរ៉ាន់ចេញពីផ្ទះរបស់ខ្លួន និងប្ដឹងទាមទារសំណងជំងឺចិត្តចំនួន ១០.០០០ដុល្លាអាមេរិក ដោយសំអាងហេតុថា ឈ្មោះ តសវថ ត្រូវជាក្មួយរបស់ខ្លួន ហើយបានស្នាក់នៅលើផ្ទះរបស់ខ្លួនហើយថែមទាំងសាងសង់តូបលក់ដូរនៅពីមុខផ្ទះរបស់ខ្លួន ហើយមានគំនិតទាមទារយកដីដែលជាកម្មសិទ្ធិផ្ទាល់របស់ខ្លួនដោយបានប្រឌិតពាក្យមិនពិតថា ជាដើមរតករបស់សព ខព ត្រូវជាម្ដាយ របស់ខ្លួននិងជាជីដូនរបស់គេ រួចប្ដឹងស៊ីបែងចែកដីនេះជាពីរចំណែក ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ២៩០ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៣ របស់តុលាការខេត្តសៀមរាប ឧត្ដរមានជ័យ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចទៅៈ

១-ទទួលពាក្យបណ្ដឹងរបស់ដើមចោទឈ្មោះ តសវថ ចុះថ្ងៃទី១២-០៨-២០០៣ ទុកជាត្រឹមត្រូវតាមទម្រង់ ប៉ុន្តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-ទទួលស្គាល់ពាក្យបណ្ដឹងសារត្រឡប់របស់ចុងចម្លើយឈ្មោះ ជគល ចុះថ្ងៃទី០៤-០៩-ឆ្នាំ ២០០៣ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

៣-ទទួលស្គាល់ផ្ទះ និងដីមួយប្លង់ទំហំ៩អារ៥២សង់ទីអារ ដែលមានព្រំប្រទល់ ខាងជើងទល់នឹងឈ្មោះ លហ ឈ្មោះ ចស,ផផរ ខាងត្បូងទល់នឹងផ្លូវជាតិលេខ៦ ឈ្មោះ លគវ ឈ្មោះ យហ ខាងកើតទល់នឹងដីឈ្មោះ លគវ និងច្រកផ្លូវ និងព្រំប្រទល់ផ្នែកខាងលិចទល់នឹងដីឈ្មោះ លសឡ ឈ្មោះ ផផរ ឈ្មោះ យយអ ស្ថិតនៅភូមិបន្ទាយចាស់ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប ឈ្មោះ ជា គឡ "ចុងចម្លើយ" មានសិទ្ធិគ្រប់គ្រងជាកម្មសិទ្ធិ ។

៤-សម្រេចឱ្យឈ្មោះ តសវថ រុះរើតូបចេញពីលើដី និងរុះរើតង់ចេញពីលើផ្ទះ របស់ឈ្មោះជា គល ចាប់ពីពេលដែលសាលក្រមចូលជាស្ថាពរ មានអានុភាពយកទៅអនុវត្ត ។

៥-បង្គាប់ឱ្យដើមចោទឈ្មោះ តសវ សងសំណងជំងឺចិត្តចំនួន៥០០ដុល្លា(ប្រាំ រយដុល្លាអាមេរិក) ទៅចុងចម្លើយឈ្មោះ ជគល ។ ស៊ីលើសពីនេះលើកចោល ។

ក្នុងករណីគ្មានប្រាក់សងទេ ត្រូវរឹបអូសទ្រព្យសម្បត្តិលក់ឡាយឡុង បើរឹងរូសត្រូវដាក់គុកបង្ខំលើរូបកាយ ។

៦-សម្រេចរឹបអូសប្រាក់ប្រដាប់ក្ដី គឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹង១៨០០៛ រង្វាន់ ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ៥.០០០៛ បូករួម.៧០០០៛ ។ ប្រាក់នេះ បានកាត់យកពីប្រាក់ ៧.០០០៛ ដែលដើមចោទបានបង់ទុករួចហើយ ។ កាលបើប្ដឹងឧទ្ធរណ៍ ត្រូវបង្គាប់ឱ្យដើមចោទបង់ពន្ធសមាមាត្រលើតម្លៃដីនិងជំងឺចិត្តដែលតុលាការបានសម្រេច ។ ប្រាក់នេះត្រូវ ដាក់ចូលថវិការដ្ឋ៨០% និងរង្វាន់ក្រឡាបញ្ជី២០% ។ ពន្ធសមាមាត្រនេះ ត្រូវឱ្យចុងចម្លើយបង់មុន ទើបបង្គាប់ឱ្យដើមចោទសងទៅចុងចម្លើយវិញជាក្រោយ ។

៧-សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខគូក្ដី បើកផ្លូវឧទ្ធរណ៍កំណត់ពីរខែ គិតពីថ្ងៃនេះតទៅ ។

បានឃើញបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៤ របស់ឈ្មោះ តសវថ ហៅ ជសវថ ប្ដឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ២៩០ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៣ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៤ របស់ឈ្មោះ ជគល ប្ដឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ២៩០ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៣ របស់តុលាការ ខេត្តសៀមរាប-ឧត្តរមានជ័យ ត្រង់ចំណុចទី៥ អំពីសំណងជំងឺចិត្ត ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៥១(ឈ) ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃសេចក្ដីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១១-០២-២០០៤ របស់ឈ្មោះ តសវថ ហៅ ជសវថ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១២-០២-២០០៤ របស់ឈ្មោះ ជគល ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

៣-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ២៩០ ចុះថ្ងៃទី២៣-១២-២០០៣ របស់តុលាការ ខេត្តសៀមរាប-ឧត្ដរមានជ័យ ទុកជាបានការដដែល ។

៤-កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ គឺពន្ធហ្នឹង និងពន្ធចុះបញ្ជីក្ដី២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ និងអាជ្ញាធរតុលាការ១០.០០០៛ សរុប ១៣.០០០៛ ។

៥-សាលដីកានេះ ជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៧-០៤-២០០៤ ចំពោះមុខចុងចម្លើយកំបាំងមុខដើមចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៦-០៥-២០០៤ ចំពោះមុខមេធាវីតំណាងចុងចម្លើយ គឺបាំងមុខដើមចោទ ។ បើកផ្លូវប្ដឹងតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងទាស់ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៤ របស់ឈ្មោះ តសវថ ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៥១(ឈ) ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍គ្រង់ចំណុចសាលដីកាទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១០៥(ឈ) ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២ច១៤ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងទាស់ចុះថ្ងៃទី២៤-៥-២០០៤ របស់ឈ្មោះ តសវថ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីកំបាំងមុខលេខ៥១(ឈ) ចុះថ្ងៃទី០៦-០៥-២០០៤ របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

៣-សាលដីកានេះ ជំនុំជំរះនៅថ្ងៃទី១៦-៧-២០០៤ ចំពោះមុខគូក្ដី និងប្រកាស ជាសាធារណៈនៅថ្ងៃទី២៨-៧-២០០៤ កំបាំងមុខគូក្ដី តែទុកជាចំពោះមុខ ។ បើកផ្លូវប្ដឹងសាទុក្ខ តាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ៣៣២ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៤ របស់ឈ្មោះ តសវថ (ហៅ ជសវត) ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ១០៩(ឈ) ចុះថ្ងៃ ទី២៧ ខែកក្កដា ឆ្នាំ ២០០៤ របស់សាលាឧទ្ធរណ៍គ្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១១៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៥ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ :

១-ទទួលបណ្តឹងសាទុក្ខលេខ៣៣២ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៤ របស់លោក ទសវថ ហៅ ជសវថ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ១០៥(ឈ) ចុះថ្ងៃទី២៧ខែកក្កដា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ៣២៩ ចុះថ្ងៃទី២០-៩-២០០៤ របស់តុលាការ កំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីដែលចុងចម្លើយ បានបង់ជួសនៅតុលាការកំពូលចំនួន១៩០០០៛ គឺ:

-ពន្ធចុះបញ្ជីក្តី នឹងពន្ធហ្នឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជា រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ។

៥-សាលដីកានេះ ជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៥ និងប្រកាស នាសវនាការជាសាធារណៈនៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៥ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៧២(ង) ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលជំនុំជំរះសំណុំរឿងក្តីរដ្ឋប្បវេណីលេខ៤០ ចុះថ្ងៃទី១៤-០៧-២០០៥ របស់សាលាឧទ្ធរណ៍តាមអំណាចសាលដីការដ្ឋប្បវេណីលេខ១១៩ ចុះថ្ងៃទី២៣-០៦-២០០៥ របស់ តុលាការកំពូលជាថ្មីឡើងវិញ ។

២-ទទួលស្គាល់ផ្ទះ និងដីមួយប្លង់ទំហំ៩អារ ៥២សង្ទីអារ ដែលមានព្រំប្រទល់ ខាងជើងទល់នឹងឈ្មោះ លហ, ឈ្មោះ ចស, បផរ ខាងត្បូងទល់ផ្លូវជាតិលេខ៦. លគន មយហ. ខាងកើតទល់នឹងដីឈ្មោះ លសឡ ឈ្មោះ បផរ, យយរ ស្ថិតនៅភូមិបន្ទាយចាស់ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប ជាកម្មសិទ្ធិរបស់ឈ្មោះ ជគល ជាចុងចំលើយនៅពេលដែលសាលដីកានេះចូលជាស្ថាពរ ។

៣-បង្គាប់ឱ្យដើមចោទឈ្មោះ តសវថ រុះរើតួបចេញពីដី និងរុះរើតង់ចេញ ពីលើផ្ទះរបស់ឈ្មោះ ជគល នៅពេលដែលសាលដីកានេះចូលជាស្ថាពរ ។

៤-បង្គាប់ឱ្យដើមចោទឈ្មោះ តសវថ សងជំងឺចិត្តចំនួន៥០០ដុល្លាអាមេរិក (ប្រាំរយដុល្លាអាមេរិក)ទៅឱ្យចុងចម្លើយ នៅពេលដែលសាលដីកានេះចូលជាស្ថាពរ។សំណូមរលើសពីនេះបដិសេធចោល ។

ក្នុងករណីគ្មានប្រាក់សង ត្រូវរឹបអូសទ្រព្យសម្បត្តិរបស់ដើមចោទលក់ឡាយឡុងយកប្រាក់ សងចុងចំលើយ ។

៥-កាត់យកប្រាក់ប្រដាប់ក្តីនៅជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន២៥៥០រ វង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន៤៥០រ ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន៥០០០រ និងលើអាជ្ញាធរតុលាការចំនួន៥០០០រ សរុប១៣០០០រ ។

បង្គាប់ឱ្យដើមចោទបង់ពន្ធសមាមាត្រ១%លើតម្លៃដីទំនាស់ និងលើប្រាក់សំណងជំងឺចិត្ត ។

៦- សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខចុងចំលើយ មេធាវីចុងចម្លើយ កំបាំងមុខដើមចោទ មេធាវីដើមចោទ ។

បានឃើញបណ្តឹងទាស់លេខ១១៨ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៥ របស់ឈ្មោះ តសវថ ប្តឹងមិនសុខចិត្តនិងសាលដីការដ្ឋប្បវេណីលេខ៧២(ង) ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ០៧(ង) ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៦ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី០៣-១១-២០០៥ របស់ឈ្មោះ តសវថ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីកំបាំងមុខលេខ៧២(ង) ចុះថ្ងៃទី២៤-១០-២០០៥ របស់សាលាឧទ្ធរណ៍ទុកជាបានការ ។

៣- សាលដីកានេះជំនុំជំរះនៅថ្ងៃទី០៦-០១-២០០៥ ចំពោះមុខគូក្តី មេធាវី ការពារក្តី និងប្រកាសជាសាធារណៈនៅថ្ងៃទី១១-០១-២០០៦ ។ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ១៩ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៦ របស់ឈ្មោះ តសវថ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ០៧(ង) ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៦ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចសេចសម្រេចទាំងមូល ។

បានឃើញបណ្តឹងសាទុក្ខលេខ៣០ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ របស់លោកមេធាវី ......... ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៧(ង) ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៦ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចមិនដាក់គុកបង្ខំរូបរាងកាយ ។

បានឃើញសារណាចុះថ្ងៃទី១៧-០២-២០០៦ របស់លោក តសវថ ។

បានឃើញសារណាតប ចុះថ្ងៃទី២៨-១៣-២០០៦ របស់ឈ្មោះ តសវថ ។

បានឃើញសារណាចុះថ្ងៃទី២០-០២-២០០៦ របស់ឈ្មោះ ដគល ។

បានឃើញសារណាតប ចុះថ្ងៃទី២០-០៣-២០០៦ របស់ឈ្មោះ ដគល ។

បានឃើញសាលដីការដ្ឋប្បវេណីរបៀបលេខ១៨០ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៦ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ចាត់របៀបធ្វើការអង្កេតបន្ថែម ហើយបើក្នុងករណីចាំបាច់ចាត់ចៅក្រមប្រឹក្សា នៃតុលាការកំពូលចុះពិនិត្យដល់ទីតាំងដីទំនាស់ ។

២-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៦ ។

បានស្តាប់របាយការណ៍បន្ថែមរបស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : រឿងនេះ គឺជារឿងសុំសិទ្ធិគ្រប់ គ្រងដើមរតក ។ សូមក្រុមប្រឹក្សាជំនុំជំរះសម្រេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ តសវថ នាពេលសវនការថា : ក្នុងរឿងនេះខ្លួនពុំមាន យោបល់ និងភស្តុតាងអ្វីបន្ថែមទៀតទេ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ជគល នាពេលសវនាការថា : ខ្លួនសុំបដិសេធនូវសំដី របស់ឈ្មោះ តមថ ដែលថា យខព បានមកសុំពីម្តាយអ្នកស្រីយក តសវថ តាំងពីតូចពីភ្នំពេញ ទៅចិញ្ចឹម ដោយ តសវត កំព្រាឪពុក-ម្តាយ ។

ចំណែករឿងថាបានទាក់ទងតាមទូរស័ព្ទជាមួយខ្លួនអំពីរឿងបែងចែកដីឱ្យឈ្មោះ តសវថ នេះគឺគ្មានទេ បានសេចក្តីថា ខ្លួនមិនឯកភាពទាំងអស់ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ឈវន ជាមេធាវីការពារឱ្យដើមចោទបានលើកឡើងថា : ចំពោះរឿងដីដែលជាដើមរតករបស់លោកយាយ ខព ដែលជាយាយបង្កើតរបស់កូនក្តីខ្លួនឈ្មោះ តសវថ នោះខ្លួនសុំសំណូមពរសុំសិទ្ធិគ្រប់គ្រងចំណែកដីមរតកសពយោយ ខព ដែលមានក្បាលដីទទឹង ៨.៤ម និងបណ្តោយ៥៤ម ក្នុងមួយចំណែកនៃទំហំដីសរុប៩៥៣ម² និងសុំបដិសេធចោលសាលដីការដ្ឋប្បវេណីលេខ០៧(ង) ចុះថ្ងៃទី១១-០១-២០០៦ របស់សាលា ឧទ្ធរណ៍ទុកជាអសារបង់ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី និងសេចក្តីសន្និដ្ឋានរបស់មេធាវីដើមចេទ .

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ១៩.ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៦ របស់លោក តសវថ និងបណ្តឹងសាទុក្ខលេខ៣០ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ របស់ ផពស មេធាវីការពារឱ្យអ្នកស្រីជា គមល ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលមានអនុភាពអនុវត្តក្នុងរឿងរដ្ឋប្បវេណីផងដែរ ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចទទួលស្គាល់សិទ្ធិរបស់ចុងចំលើយលើដីទំនាស់ទាំងមូលនិងបង្គាប់ឱ្យដើមចោទលោក តសវត រុះរើតូបរបស់ខ្លួនចេញពីដី និងរុះរើតវ៉ាន់ចេញពីផ្ទះរបស់ចុងចម្លើយដោយសំអាងហេតុថា ដី និងផ្ទះនេះពិតជាត្រូវបានទិញដោយចុងចម្លើយពីម្ចាស់ដើមឈ្មោះ បរ តាំងពីឆ្នាំ១៩៨១ មកនោះពុំមានលក្ខណៈត្រឹមត្រូវទេ ពីព្រោះថា ចម្លើយរបស់អ្នកស្រី បរ មានការប្រែប្រួលពុំអាចយកជាការបានទេ ។

- យល់ឃើញថា ចុងចម្លើយពុំបានកាន់កាប់ដី និងផ្ទះទំនាស់នេះ ផ្តាច់មុខតែម្នាក់ឯង តាំងពីឆ្នាំ១៩៨១ មកទេ គឺដើមចោទក៏បានកាន់កាប់ និងស្នាក់នៅលើដីនិងផ្ទះនេះដែរ ។

- យល់ឃើញថា ដើមចោទលោក តសវថ ពិតជាបានមករស់នៅជាមួយចុងចម្លើយពី ឆ្នាំ១៩៧៩ ឬ ១៩៨១ ប្រាកដមែន ថ្វីបើដើមចោទបានចាកចេញពីផ្ទះនេះនៅឆ្នាំ១៩៨៣ ក៏ពិតមែន ប៉ុន្តែបានត្រឡប់មករស់នៅបន្តពីឆ្នាំ១៩៨៨ រហូតបច្ចុប្បន្នផងដែរ ។

- យល់ឃើញថា ក្នុងការរស់នៅជាមួយចុងចម្លើយ ដើមចោទក៏ធ្លាប់បានចាត់ចែងនូវ ការងារខ្លះៗ លើផ្ទះនិងដីទំនាស់នេះដែរ ដោយពុំមានការហាមឃាត់ ឬ រារាំងពីចុងចំលើយទេ ។

- យល់ឃើញថា ថ្វីបើដើមចោទបានស្នាក់នៅ និងចាត់ចែងការងារខ្លះលើដីទំនាស់ក៏ពិតមែន ប៉ុន្តែដើមចោទពុំអាចទទួលសិទ្ធិស្មើនឹងចុងចម្លើយដែលជាមេគ្រួសារនោះទេ ដែលគប្បីតុលាការកំពូលពិចារណានិងសម្រេចតាមភាពសមហេតុសមផល ។

- យល់ឃើញ សាលដីការដ្ឋប្បវេណីលេខ០៧(ង) ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៦របស់សាលាឧទ្ធរណ៍ ដែលសម្រេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេមក្តចំពោះមុខគូក្ត

១-ទទួលបណ្តឹងសាទុក្ខលេខ១៩ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៦របស់លោក តសវថ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-ទទួលបណ្តឹងសាទុក្ខលេខ៣០ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦របស់លោកមេធាវី ផពស ការពារឱ្យអ្នកស្រី ជកល ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយ ខុសនឹងគតិច្បាប់ ។

៣-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ០៧(ង) ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៦ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៤-បែងចែកដដីABNM ដែលមាAM=BN=6ម និងAM=BN40,50ម តាមគំនូសប្លង់ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៦ របស់ចៅក្រមប្រឹក្សាតុលាការកំពូល និងដីចំណីផ្លូវខាង មុខដីនេះឱ្យទៅឈ្មោះ តសវថ កាន់កាប់ និងគ្រប់គ្រងតទៅ និងប្រគល់ចំណែកនិងដីចំណីថ្នល់ ដែលនៅសល់ និងផ្ទះព្រមទាំងការ្យផ្សេងៗទៀតឱ្យទៅចុងចម្លើយអ្នកស្រី ជគល កាន់កាប់ និងគ្រប់គ្រងតទៅ ។

៥-បង្គាប់ឱ្យដើមចោទលោក តសវថ រុះរើតួបរបស់ខ្លួនមកដាក់លើដីចំណែកដែល តុលាការប្រគល់ឱ្យនៅចំណុចទី៤ ខាងលើនិងឱ្យឈ្មោះនេះរើតវ៉ាន់របស់ខ្លួនចុះចេញពីផ្ទះដែលប្រគល់ ឱ្យអ្នកស្រី ជគល ។

៦-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន៣៨.០០០រដែលអ្នកស្រី ជគម បានបង់គឺ :

-ពន្ធចុះបញ្ជីក្តី នឹងពន្ធហ្នឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ នៅសល់១៩.០០០៛ ប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ ជគល វិញ ។

បង្គាប់ឲ្យអ្នកស្រី ជគល បង់ពន្ធសមាមាត្រ១%លើតម្លៃដីABNM ដែលត្រូវប្រគល់ឱ្យឈ្មោះ កសវថ និងបង្គាប់ឱ្យ តសវថ បង់ពន្ធសមាមាត្រមួយភាគរយលើតម្លៃដីទំហំ៤០,៥០ម x២,៤០ម ។

៧-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០៦។